CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 13 ខែឧសភា ឆ្នាំ 2021
ទំនាក់ទំនង ៖ ស៊ូហ្សាន ចូន (Susan Jones), 562.570.6608, Susan.Jones@lbpl.org

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# បណ្ណាល័យសាធារណៈ ឡុងប៊ិច ធ្វើការអបអរសាទរខួបទី ១២៥ ឆ្នាំនៃសេវាកម្មរបស់ខ្លួន

ឡុងប៊ិច, CA - បណ្ណាល័យសាធារណៈ ឡុងប៊ិច (LBPL) នឹងធ្វើការអបអរសាទរខួបទី ១២៥ ឆ្នាំនៃសេវាកម្ម ជូនសហគមន៍ និងសូមអញ្ជើញសាធារណជន ឱ្យតាមទំព័របណ្តាញសង្គម របស់បណ្ណាល័យ ដើម្បីទទួលបានព័ត៌មាន បច្ចុប្បន្នភាព និងដំណឹងគួរឱ្យភ្ញាក់ផ្អើល ចុងក្រោយបំផុត ដើម្បីចូលរួម ពិធីអបអរសាទរនេះ ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Robert Garcia) បានគូសបញ្ជាក់ថា «ក្នុងរយៈពេល 125 ឆ្នាំ ឡុងប៊ិចបានផ្តល់តម្លៃ ដល់ឧត្តមភាព នៃបណ្ណាល័យសាធារណៈ ដូចជា លទ្ធភាពចូលប្រើប្រាស់, ភាពចម្រុះ, សេរីភាពផ្នែកបញ្ញា, ឯកជនភាព, ការសិក្សា ពេញមួយជីវិត, សេវា និងការទទួលខុសត្រូវ ផ្នែកសង្គម ។» «យើងពិតជាមានសំណាងណាស់ ដែលយើងមាន បណ្ណាល័យសាធារណៈ ឡុងប៊ិច ដែលមានការទទួលស្គាល់ ថ្នាក់ជាតិ ជាយូរយាមកហើយនេះ ជាផ្នែកគោលមួយ នៃសេវារបស់យើង ជូនសហគមន៍ ។»

ដើម្បីអបអរសាទរ ខួបទី 125 ឆ្នាំ ជាពិធីរំឭកខួប នៅឆ្នាំនេះ, គេហទំព័រ របស់ LBPL នឹងចងក្រងឯកសារ អំពីប្រវត្តិសាស្ត្រ និងការលូតលាស់ របស់បណ្ណាល័យសាធារណៈ ឡុងប៊ិច ដោយបន្ថែមខ្លឹមសារប្រចាំខែថ្មី និងចែករំលែក សកម្មភាពកំសាន្តសប្បាយ សម្រាប់កុមារយុវជន និងមនុស្សធំពេញវ័យ រួមទាំង មូលហេតុ ចំនួន 125 ក្នុងការអបអរសាទរបណ្ណាល័យរបស់លោកអ្នក, សៀវភៅ ទាំង 125 ក្បាល សម្រាប់អបអរសាទរ និង ចំណោទស្វែងរកពាក្យខួប LBPL ។ ប្រជាពលរដ្ឋ ក៏ត្រូវបានលើកទឹកចិត្ត ឱ្យតាមដានពិធីអបអរសាទរនេះ ដោយតាម LBPL នៅលើ Facebook, Instagram និង Twitter ។

ហ្គ្លេនដា វិលលៀម (Glenda Williams) ប្រធានបណ្ណាល័យសាធារណៈ ឡុងប៊ិច បានលើកឡើងថា «ប្រព័ន្ធបណ្ណាល័យរបស់យើង បានរីកលូតលាស់ យ៉ាងសម្បើម ក្នុងរយៈពេល 125 ឆ្នាំមកនេះ ហើយបានសម្របខ្លួន និងធ្វើការផ្លាស់ប្តូរ ទៅតាមសេចក្តីត្រូវការ របស់សហគមន៍យើង ។» «ចាប់តាំងពីពេលចាប់ផ្តើមដំបូង ក្នុងកម្រិតតិចតួចមក បណ្ណាល័យនេះ បានផ្តល់អត្ថន័យខ្លឹមសារ ជូនអ្នកគ្រប់គ្នា ហើយនឹងបន្តធ្វើបែបនេះទៀត ។»

នៅឆ្នាំ 1895 ក្រុម «ពលរដ្ឋស្នេហាជាតិ និងប្រាកដនិយម» បានរួបរួមគ្នា បង្កើតសមាគមបណ្ណាល័យ ឡុងប៊ិច ដោយសង្ឃឹមថា នឹងផ្តល់បន្ទប់អាន នៅបណ្ណាល័យ ជូនប្រជាពលរដ្ឋ របស់ក្រុង ចំនួន 1,500 នាក់ ។ នៅថ្ងៃទី 1 ខែមករា ឆ្នាំ 1896 ពួកគេបានបើកដំណើរការ បណ្ណាល័យ ទីមួយ នៅឡុងប៊ិច ក្នុងផ្ទះឈើ បំភ្លឺដោយចង្កៀងប្រេងកាត ក្នុងតំបន់ឆ្នេរសមុទ្រ នៅចន្លោះរុក្ខវិថីប៉ាស៊ីហ្វិក និងវិថីផាញន៍ (Pine) ដោយមានកម្រងសៀវភៅផ្សេងៗ ចំនួន 200 ក្បាល មកពីវិហារ ហ្វឺស ខនគ្រីហ្គេសុនណល (First Congregational Church) ។

សព្វថ្ងៃនេះ កម្រងសម្បត្តិ របស់ LBPL មានវត្ថុ ច្រើនជាងចំនួន 800,000 ហើយរួមមានជា ឯកសារបោះ
ពុម្ព, ខ្សែអាត់, DVDs,សៀវភៅអេឡិចត្រូនិក, សៀវភៅសម្លេង ដែលអាចទាញយកបាន, និងហតស្ប៉តអ៊ី
នធឺណែត ឥតខ្សែ ដែលមានផ្តល់ជូន សម្រាប់ខ្ចីទៅប្រើប្រាស់បាន ។ បណ្ណាល័យឌីជីថល រួមមាន ធនធាន
សម្រាប់ការរៀនភាសា, ធ្វើកិច្ចការគ្រូដាក់ឱ្យធ្វើនៅផ្ទះ និងជំនួយ ផ្នែកការងារ, ថ្នាក់បង្រៀនវិជ្ជាជីវៈ និង
បច្ចេកទេស, សកម្មភាពធ្វើពេលទំនេរ, កម្រងសិក្សា អំពីសាច់សារលោហិតគ្រួសារ និងព័ត៌មាន ។

នាពេលបច្ចុប្បន្ននេះ ប្រព័ន្ធបណ្ណាល័យសាធារណៈ ឡុងប៊ិច រួមមាន បណ្ណាល័យចំបង ប៊ីលលី ជែន ឃីង
(Billie Jean King) នៅតំបន់ទីប្រជុំជន និង បណ្ណាល័យតាមភូមិស្ថាន ចំនួនដប់មួយ នៅទូទាំងទីក្រុង ។
សម្រាប់ព័ត៌មានបន្ថែមទៀត អំពីខួប ឬសេវាបច្ចុប្បន្ន របស់បណ្ណាល័យ រួមទាំង LBPL To-Go និង Tech
To-Go សូមចូលទៅ www.lbpl.org ឬ ទូរសព្ទទៅលេខ 562.570.7500 ។

**អំពីទីក្រុងឡុងប៊ិច**

មានប្រជាជនប្រមាណ 470,000 នាក់ សាលាក្រុងឡុងប៊ិច ដែលបានទទួលបានពានរង្វាន់ និងច្នៃប្រឌិត
ថ្មីជាច្រើន បានផ្តល់ជូននូវភាពសំបូរបែបនៃពិភពលោកនៃទីក្រុងធំមួយ ខណៈពេលដែលរក្សាបាននូវ
លក្ខណៈភាពជាបុគ្គល និងមានចម្រុះដោយភូមិស្ថានផ្សេងៗគ្នាផ្តុំគ្នានៅតាមបណ្តោយឆ្នេរសមុទ្រ
California។ ក្នុងនាមជាទីក្រុងដែលផ្តល់សេវាកម្មពេញលេញ, ទីក្រុងឡុងប៊ិច ជាទីតាំងនៃសារមន្ទីរ និង
មហោស្រពជាច្រើន ដូចជា Queen Mary, Aquarium of the Pacific, និងមានកន្លែងជាច្រើនទៀត
មណ្ឌលសាលារៀនដែលត្រូវបានគេវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច និងកំពង់ផែឡុងប៊ិច។ មន្ទីរ
សាលាក្រុង បានឈ្នះពានរង្វាន់ជាច្រើន ផ្សេងទៀតដូចជាសុខភាព សួនឧទ្យាន កំពង់ផែកំសាន្ត និងសេ
វាកម្មអភិវឌ្ឍន៍ និងផ្សេងៗទៀត។ ទីក្រុង ក៏មានសាកលវិទ្យាល័យ និងមហាវិទ្យាល័យដែលត្រូវបានគេវាយ
តម្លៃខ្ពស់, មានកន្លែងកសិដ្ឋានចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រពីរកន្លែង, មន្ទីរពេទ្យប្រាំ កន្លែង, ទីវាលហ្គឹក
ហាត់វាយកូនហ្គោលប្រាំ កន្លែង, សួនច្បារ 171, ឆ្នេរសមុទ្ររាប់សិបម៉ាយល៍, កំពង់ផែសម្រាប់លំហែកំសាន្ត
ជាច្រើនកន្លែង, គន្លងផ្លូវជិះកង់ និងកម្មវិធីចែកចាយកង់។

សម្រាប់ព័ត៌មានបន្ថែមទៀត អំពីទីក្រុងឡុងប៊ិច សូមចូលទៅ http://longbeach.gov/ ។ សូមតាមយើង
ខ្ញុំ នៅលើបណ្តាញសង្គមដើម្បីទទួលបានព័ត៌មានចុងក្រោយបំផុតនានា ៖ Facebook, Twitter,
Instagram និង YouTube ។

**អំពីបណ្ណាល័យសាធារណៈ ឡុងប៊ិច**

បណ្ណាល័យសាធារណៈ ឡុងប៊ិច ដែលបានបង្កើតឡើង នៅឆ្នាំ 1896 បម្រើជូន ទីក្រុងចម្រុះលក្ខណៈ ដែល
មានប្រជាពលរដ្ឋ ជិតកន្លះលាននាក់ ។ ប្រព័ន្ធបណ្ណាល័យសាធារណៈ ឡុងប៊ិច រួមមាន បណ្ណាល័យចំបង ប៊ី
លលី ជែន ឃីង (Billie Jean King) ព្រមទាំង បណ្ណាល័យតាមភូមិស្ថាន ចំនួនដប់មួយ និងវត្តមាន តាមអ៊ី
នធឺណែត យ៉ាងរស់រវើក ។ នៅរដូវក្តៅ ក្នុងឆ្នាំ 2017 បណ្ណាល័យសាធារណៈ ឡុងប៊ិច ទទួលបាន មេដាយ
ជាតិ សម្រាប់សេវាបណ្ណាល័យ និងសារមន្ទីរ ដែលទទួលស្គាល់ កិច្ចសហការសហគមន៍ ជោគជ័យ, STEM
(វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា) ប្រកបដោយនវានុវត្តន៍ និងកម្មវិធីផ្តោតលើអក្ខរកម្ម
សម្រាប់ប្រជាពលរដ្ឋឡុងប៊ិច ។ ដោយផ្តោតលើការផ្តល់លទ្ធភាពចូលប្រើប្រាស់ ដោយឥតគិតថ្លៃ និងស្មើ
ភាពគ្នា ចំពោះព័ត៌មាន និងការគាំទ្រ សម្រាប់ការសិក្សា អស់មួយជីវិត, បណ្ណាល័យផ្តល់ជូន សៀវភៅ, ឯក
សារផ្សព្វផ្សាយ, ទិន្នន្នដ្ឋាន, លទ្ធភាពទទួលបានអ៊ីនធឺណែត, មជ្ឈមណ្ឌលសិក្សា លក្ខណៈគ្រួសារ, ទីកន្លែង
សម្រាប់សិប្បករ, និងព្រឹត្តិការណ៍ផ្សេងៗ ទៀត ជាច្រើន ចាប់ពីនាទីនិទានរឿងរហូតដល់ កម្មវិធីអប់រំ
និងវប្បធម៌ ។

CITY OF LONG BEACH

# PRESS RELEASE

សម្រាប់ព័ត៌មានបន្ថែមសូមទស្សនា http://www.longbeach.gov/library, “Like” បណ្ណាល័យសាធារណៈ នៅឡុងប៊ិចនៅលើ Facebook, និងតាមយើង Twitter និង Instagram. ។

###